ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

********

រដ្ឋសភា

សេចក្ដីស្នើច្បាប់

# ច្បាប់

# ធម្មនុញ្ញ

# នៃព្រះរាជាណាចក្រកម្ពុជា

# ស្ដីពី

# វិសោធនកម្ម

មាត្រា ១១ថ្មី មាត្រ៉ា ១២ថ្មី មាត្រា ១៣ថ្មី មាត្រា ២៣ មាត្រា ២៤ថ្មី មាត្រា ២៨ថ្មី មាត្រា ២៩ មាត្រា ៣០ថ្មី មាត្រា ៣៤ថ្មី មាត្រា ៧៦ មាត្រា ៩៨ មាត្រា ៩៩ថ្មី មាត្រា ១០០ថ្មី មាត្រា ១០១ថ្មី មាត្រា ១០២ថ្មី មាត្រា ១១៨ថ្មី មាត្រា ១១៩ថ្មី មាត្រា ១២៨ថ្មី មាត្រា ១៣៣ថ្មី មាត្រា ១៣៤ថ្មី មាត្រា ១៤៦ថ្មី និង មាត្រា ១៥៨ថ្មី នៃរដ្ឋធម្មនុញ្ញ ៕

**មាត្រាតែមួយ.-**

**មាត្រា ១១.- ថ្មី**

ក្នុងករណីដែលព្រះមហាក្សត្រពុំអាចបំពេញព្រះរាជភារៈ ជាព្រះប្រមុខរដ្ឋបានដូចធម្មតា ដោយព្រះអង្គទ្រង់ប្រឈួនជាទម្ងន់ *ឬដោយព្រះអង្គពុំស្ថិតនៅក្នុងប្រទេសនោះ ព្រះមហាក្សត្រតែងតាំងព្រះរាជបព្វជិតមួយព្រះអង្គឱ្យបំពេញភារកិច្ចប្រមុខរដ្ឋស្ដីទី ។*

*ប្រសិនបើព្រះមហាក្សត្រពុំបានតែងតាំងប្រមុខរដ្ឋស្ដីទីទេនោះ ក្រុមប្រឹក្សាព្រះមហាក្សត្រត្រូវតែងតាំងព្រះរាជវង្សានុវង្សមួយព្រះអង្គឱ្យបំពេញភារកិច្ចនេះ ក្នុងព្រះបរមនាមព្រះមហាក្សត្រ ។ រាល់មុនចូលកាន់តំណែងប្រមុខរដ្ឋស្ដីទីត្រូវធ្វើសច្ចាប្រណិធានដូចតទៅ :*

ព្រះមហាក្សត្រទ្រង់ចាត់តាំងវរជនមួយរូប ក្នុងចំណោមតំណាងរាស្ត្រនៃគណបក្សឈ្នះឆ្នោតឱ្យបង្កើតរាជរដ្ឋាភិបាល ។ វរជនដែលត្រូវបានចាត់តាំងនេះ នាំសហការីដែលជាតំណាងរាស្ត្រឬជាសមាជិកគណបក្សតំណាងនៅក្នុងរដ្ឋសភា ដែលផ្ទួរផ្ដងឱ្យកាន់តំណែងផ្សេងៗក្នុងរាជរដ្ឋាភិបាល ទៅសុំសេចក្ដីទុកចិត្តពីរដ្ឋសភា ។ កាលបើរដ្ឋសភាបានបោះឆ្នោតទុកចិត្តហើយនោះ ព្រះមហាក្សត្រទ្រង់ចេញព្រះរាជក្រឹត្យតែងតាំងគណៈរដ្ឋមន្ត្រីទាំងមូល ។ *តែបើរដ្ឋសភាពុំបានបោះឆ្នោតផ្ដល់សេចក្ដីទុកចិត្តវិញនោះ វរជនជាបេក្ខភាពនាយករដ្ឋមន្ត្រី ពុំអាចមកសុំសេចក្ដីទុកចិត្តពីរដ្ឋសភាលើសពីពីរដងបានឡើយ ។*

*បើមានរាជរដ្ឋាភិបាលចំរុះ ហើយក្នុងករណីដែលមានគណបក្សណាមួយប្រកាសដកខ្លួនចេញ រាជរដ្ឋាភិបាលនោះ ត្រូវសុំសេចក្ដីទុកចិត្តពីរដ្ឋសភាជាថ្មីឡើងវិញ យ៉ាងយូរក្នុងរយៈពេលសាមសិប(៣០)ថ្ងៃ ក្រោយការប្រកាសនេះ ។ ក្នុងករណីដែលពុំមានការគាំទ្រផ្ដល់សេចក្ដីទុកចិត្តពីរដ្ឋសភាជាថ្មីឡើងវិញនោះ ព្រះមហាក្សត្រត្រូវចាត់តាំងវរជនមួយរូបឱ្យដឹកនាំកិច្ចការប្រចាំថ្ងៃនៃរាជរដ្ឋាភិបាលបណ្ដោះអាសន្ន រហូតរាជរដ្ឋាភិបាលថ្មីមួយត្រូវបានបង្កើតឡើងស្របតាមនីតិវិធីដូចមានចែងខាងលើ ។*

មុនចូលកាន់តំណែងគណៈរដ្ឋមន្ត្រីត្រូវធ្វើសច្ចាប្រណិធានដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធ ៦ ។